# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីសម្រេចបញ្ចប់អាជ្ញាប័ណ្ណរួមលេខ ០៩២ ឯអ
# ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤ សម្រាប់ធ្វើសេវាកម្មផលិត
# និងចែកចាយអគ្គិសនីនៅទីរួមខេត្តឧត្តរមានជ័យ
# របស់លោក សោម វិសាល
# អាជ្ញាធរអគ្គិសនីកម្ពុជា

-អនុវត្តតាមមាត្រា ៧ និង ៣០ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-យោងឯកសារអាជ្ញាប័ណ្ណរួមរបស់លោក សោម វិសាល លេខ ០៩២ឯអ ចុះ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤

-យោងលិខិតរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលលេខ ២៧១ឧរស.អថ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៥

-យោងកិច្ចសន្យាផ្ទេរសិទ្ធិរបស់លោក សោម វិសាល និងក្រុមហ៊ុនឌូធីហ្វ្រីសប់ ចុះ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៥

-យោងលិខិតស្នើសុំផ្ទេរសិទ្ធិគ្រប់គ្រងសេវាកម្មអគ្គិសនីរបស់លោក សោម វិសាល ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៥

-យោងតាមការអនុម័តរបស់សម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជា លើកទី៩៤ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៧

## សម្រេច

### ប្រការ១

ដកហូតអាជ្ញាប័ណ្ណសម្រាប់ធ្វើសេវាកម្មផលិត និងចែកចាយអគ្គិសនីនៅទីរួមខេត្តឧត្តរមានជ័យ ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណរួមលេខ ០៩២ ឯអ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤ របស់លោក សោម វិសាល ។ លោក សោម វិសាល បានស្នើសុំអាជ្ញាធរអគ្គិសនីកម្ពុជាដកហូតអាជ្ញាប័ណ្ណរបស់លោក ហើយផ្ទេរសិទីធ្វើសេវាកម្មអគ្គិសនីខាងលើទៅឱ្យក្រុមហ៊ុន **ឌូធីហ្វ្រីសប់** មានទីស្នាក់ការនៅ ភូមិចាំយាម ឃុំបាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ដែលបានចុះបញ្ជីពាណិជ្ជកម្មលេខ Inv-706/00 P ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០០ នៅក្រោមបទប្បញ្ញត្តិ នៃក្រុមពាណិជ្ជកម្ម និងរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ។ លោក សោម វិសាល បានលើកហេតុផលថា លោកមិនមានទុនគ្រប់គ្រាន់ក្នុងការសាងសង់បណ្តាញបញ្ជូន ដើម្បីបញ្ជូនអគ្គិសនីដែលមានថ្លៃថោកនាំចូលពីប្រទេសថៃ ។ ក្រុមហ៊ុន**ឌូធីហ្វ្រីសប់** បានយល់ព្រមសាងសង់ខ្សែបណ្តាញបញ្ជូន និងធ្វើការផ្គត់ផ្គង់អគ្គិសនីនៅទីរួមខេត្តឧត្តរមានជ័យ។ អាជ្ញាធរអគ្គិសនីកម្ពុជា ទទួលស្គាល់នូវហេតុផលខាងលើ ដើម្បីអនុញ្ញាតិឱ្យលោក សោម វិសាល បញ្ចប់សិទ្ធិក្នុងការធ្វើសេវាកម្មផលិត និងចែកចាយអគ្គិសនីនៅទីរួមខេត្តឧត្តរមានជ័យ ហើយផ្ទេរសិទ្ធិធ្វើសេវាកម្មអគ្គិសនីនេះទៅឱ្យក្រុមហ៊ុន **ឌូធីហ្វ្រីសប់** ។

**ប្រការ២**

លោក សោម វិសាល នឹងលែងមានសិទ្ធិធ្វើសេវាកម្មអគ្គិសនីនៅទីរួមខេត្ត ឧត្តរមានជ័យ ដូចបានបញ្ជាក់ក្នុងអាជ្ញាប័ណ្ណ រួមលេខ ០៩២ ឯអ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤ ចាប់ពីថ្ងៃដែលលោក សោម វិសាល ផ្ទេរអាជីវកម្មផ្គត់ផ្គង់ អគ្គិសនីទាំងស្រុងនៅទីរួមខេត្ត ឧត្តរមានជ័យទៅឱ្យក្រុមហ៊ុន **ឌូធី ហ្វ្រីសប់** ។ លោក សោម វិសាល ត្រូវផ្តល់ច្បាប់ ចំលងនៃកិច្ចសន្យាផ្ទេរអាជីវកម្មអគ្គិសនីជាមួយ ក្រុមហ៊ុន **ឌូធី ហ្វ្រីសប់** ជូនអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីសុំការអនុម័ត។

**ប្រការ៣**

សេចក្តីសម្រេចនេះចូលជាធរមាន ចាប់ពីថ្ងៃដែលអាជ្ញាធរអគ្គិសនីកម្ពុជា យល់ព្រមលើកិច្ចសន្យាផ្ទេរអាជីវកម្មអគ្គិសនី របស់លោក សោម វិសាល និង ក្រុមហ៊ុន **ឌូធី ហ្វ្រីសប់** ។

**ប្រការ៤**

អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើសេចក្តីសម្រេចនេះ ទៅតំកល់ទុកបន្ថែមនៅតាមទីកន្លែង ដែលឯកសារអាជ្ញាប័ណ្ណលេខ ០៩២ឯអ បានតំកល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ ០៩២ឯអ ដែលតំកល់ទុកនោះត្រូវអស់សុពលភាពស្រប តាមសេចក្តីសម្រេចនេះ ។

ភ្នំពេញ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៧

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**